ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា
លេខ : ២៣៤០១/១៧ អ គ រ

រាជធានីភ្នំពេញ, ថ្ងៃទី៣១ខែតុលា ឆ្នាំ២០១៧

## សេចក្តីជូនដំណឹង

អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា (អគរ) មានកិត្តិយសសូមជម្រាបជូនដល់សាធារណជន ជាពិសេសពាណិជ្ជករ និងប្រតិបត្តិករដឹកជញ្ជូនទំនិញ នាំចេញនាំចូលពាក់ព័ន្ធទាំងអស់ឱ្យបានជ្រាបថា ច្បាប់គយថ្មីរបស់ប្រទេសថៃដែលនឹងចូលជាធរមាននៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៧ ខាងមុខនេះ មានបញ្ញត្តិហាមឃាត់ការដឹកជញ្ជូនទំនិញឆ្លងកាត់ប្រទេសថៃតាមផ្លូវគោក។ ក្នុងន័យនេះ អាជ្ញាធរថៃនឹងមិនអនុញ្ញាតឱ្យមានការដឹកជញ្ជូនទំនិញពីប្រទេសទីបីឆ្លងកាត់ប្រទេសថៃដើម្បីនាំចូលមកកម្ពុជា និងការដឹកជញ្ជូនទំនិញរបស់កម្ពុជាឆ្លងកាត់ប្រទេសថៃដើម្បីនាំចេញទៅប្រទេសទីបីឡើយ ប្រសិនបើពុំមានមានកិច្ចព្រមព្រៀង/អនុស្សារណៈនៃការយោគយល់គ្នាស្តីពី ការដឹកជញ្ជូនទំនិញឆ្លងកាត់រវាងប្រទេសទាំងពីរ ។

ដើម្បីធានានិរន្តរភាពនៃប្រតិបត្តិការដឹកជញ្ជូនទំនិញនាំចេញនាំចូលរបស់កម្ពុជាឆ្លងកាត់ប្រទេសថៃ ដូចដែលធ្លាប់បានអនុវត្តកន្លងមក និងស្របតាមស្មារតី និងខ្លឹមសារសេចក្តីប្រកាសរួមនៃកិច្ចប្រជុំគណៈរដ្ឋមន្ត្រីចម្រុះកម្ពុជា-ថៃ ដែលបានប្រព្រឹត្តទៅកាលពីថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៧ នៅទីក្រុងភ្នំពេញ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាបាននិងកំពុងខិតខំជំរុញអស់ពីលទ្ធភាព ក្នុងការចរចាជាមួយសមភាគីថៃ ដើម្បីរៀបចំអនុស្សារណៈនៃការយោគយល់គ្នាស្តីពីការដឹកជញ្ជូនទំនិញឆ្លងកាត់ ដែលគ្រោងចុះហត្ថលេខាឱ្យបានមុនកាលបរិច្ឆេទចូលជាធរមាននៃច្បាប់គយថ្មីរបស់ប្រទេសថៃ។ ទោះបីជារដ្ឋបាលគយនៃប្រទេសទាំងពីរបានឯកភាពគ្នាលើខ្លឹមសាររួចហើយកាលពីថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៧ក៏ដោយ រហូតមកដល់ពេលនេះ អនុស្សារណៈនៃការយោគយល់គ្នានេះនៅកំពុងរង់ចាំសេចក្តីសម្រេចពីភាគីថៃនៅឡើយ ។

យោងតាមពេលវេលាកាន់តែកៀក ហើយរដ្ឋបាលគយថៃនៅតែពុំទាន់ទទួលបានការអនុញ្ញាតពីថ្នាក់លើរបស់ខ្លួនឱ្យ ចុះហត្ថលេខាលើអនុស្សារណៈយោគយល់គ្នានោះ អគរ សម្រេចចេញសេចក្តីជូនដំណឹងនេះ ដែលមានគោលបំណងជម្រាបជូនដល់ធុរជនពាក់ព័ន្ធឱ្យមានការត្រៀមទុកជាមុនជាយថាហេតុក្នុងការកែប្រែតម្រាយផ្លូវដឹកជញ្ជូនទំនិញរបស់ខ្លួន ឱ្យបានសមស្របនិងទាន់ពេលវេលា ជៀសវាងនូវការរងបង់យអវិជ្ជមាននានា ដែលបណ្តាលមកពីការហាមឃាត់/រឹតបណ្តឹង ការដឹកជញ្ជូនទំនិញពីប្រទេសទីបីឆ្លងកាត់ប្រទេសថៃ ដើម្បីនាំចូលមកកម្ពុជា ឬពីកម្ពុជាឆ្លងកាត់ប្រទេសថៃទៅកាន់ប្រទេសទីបី ក្នុងករណីដែលការចុះហត្ថលេខាលើអនុស្សារណៈនៃការយោគយល់គ្នានេះពុំអាចធ្វើបានទាន់ពេលវេលាដូចការរំពឹងទុក។

អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជានឹងបន្តជំរុញសមភាគីថៃ ឱ្យពន្លឿនការសម្រេចលើការចុះហត្ថលេខាលើអនុស្សារណៈនៃការយោគយល់គ្នានេះ ឱ្យបានឆាប់បំផុតតាមការដែលអាចធ្វើទៅបាន ហើយនឹងជូនដំណឹងភ្លាមពីវឌ្ឍនភាពចុងក្រោយ នាពេលឆាប់ៗខាងមុខនេះ ។ អាស្រ័យហេតុនេះ សូមអស់លោក លោកស្រី ជាធុរជនពាក់ព័ន្ធទាំងអស់ជ្រាបជាព័ត៌មាន ។

អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា